ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
**Ministry of Commerce**
No. ១៥៣ MOC / SM 2006

# ប្រកាស
## ស្តីពី
## សារធាតុគីមីហាមប្រើលើផលិតផលម្ហូបអាហារ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៧០៤/ ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០៦០០ / ០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និងសេវា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកម/ ០១៩៦/ ១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ០៣ ស.រ ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីការ គ្រប់គ្រងគុណភាព និងវិធានការត្រួតពិនិត្យគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងចំណីអាហារ ដែលមានប្រើសារជាតិគីមី
- បានឃើញប្រកាសលេខ ០១២ ពណ.បណ.ប្រក ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនាំចេញនាំចូល និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល)


Ministry of Commerce
20 A & B Preah Norodom Boulevard
Phnom Penh 12205
Kingdom of Cambodia
Senior Minister's Cabinet
Tel: (855) 23 427 358/214 946
Fax: (855) 23-213-288/991-708

- ដើម្បីការពារសុខភាព និងសុវត្ថិភាពប្រជាពលរដ្ឋពីគ្រោះបង្កឡើងដោយសារធាតុគីមី ដែលមានសក្តានុពលហានិភ័យក្នុងផលិតផលម្ហូបអាហារ

## <u>សំរេច</u>

### ប្រការ ១.-

ហាមឃាត់ការដាក់បញ្ចូល ការដាក់អោយប៉ះពាល់ទៅនឹងផលិតផលម្ហូបអាហារដោយប្រការណាក៏ដោយ រឺការរក្សាទុកដោយពុំមានហេតុផលត្រូវច្បាប់នូវសារធាតុគីមីទាំងឡាយដូចមានកំណត់ ក្នុងឧបសម្ព័ន្ធ១នៅគ្រប់ ទីកន្លែងផលិត កែច្នៃ និងលក់។

### ប្រការ ២.-

ហាមធ្វើចរាចរចំពោះផលិតផលម្ហូបអាហារ ដែលមានវត្តមានសារធាតុគីមីដែលបានហាមឃាត់ដូចមានចែងនៅក្នុងប្រការ ១ ។

### ប្រការ ៣.-

ការនាំចូលផលិតផលម្ហូបអាហារដែលកំណត់ក្នុងឧបសម្ព័ន្ធ២ ត្រូវមានភ្ជាប់មកជាមួយនូវរបាយការណ៍វិភាគបង្ហាញថាពុំមានវត្តមានសារធាតុគីមី PARA RED, RHODAMINE B, SUDAN I, SUDAN II, SUDAN III និង SUDAN IV ។

របាយការណ៏វិភាគនោះ ត្រូវមានបញ្ជាក់យល់ព្រមដោយអាជ្ញាធរមានសមត្ថកិច្ចត្រួតពិនិត្យសុវត្ថិភាពផលិតផលម្ហូបអាហារនៃប្រទេសនាំចេញ។

### ប្រការ ៤.-

ការនាំចូលសារធាតុគីមីដូចកំណត់ក្នុងប្រការ១ខាងលើ ត្រូវមានភ្ជាប់នូវឯកសារប្រកបដោយលក្ខណៈត្រឹមត្រូវបញ្ជាក់ ទិសដៅប្រើប្រាស់ត្រូវច្បាប់សំរាប់សារធាតុគីមីនោះ។

### ប្រការ ៥.-

អគ្គនាយកបច្ចេកទេស អគ្គនាយករដ្ឋបាល-ហិរញ្ញវត្ថុ អគ្គាធិការ នាយិការខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធាននាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនិហរ័ណ្ណ-អាហារ័ណ្ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាព ។



Ministry of Commerce
20 A & B Preah Norodom Boulevard
Phnom Penh 12205
Kingdom of Cambodia

Senior Minister's Cabinet
Tel: (855) 23 427 358/214 946
Fax: (855) 23-213-288/991-708
E-mail: moccabdin@yahoo.com

**ប្រការ ៦.**

ប្រកាសនេះមានអនុភាពគតិយុទ្ធចាប់ពីថ្ងៃចុះហត្ថលេខាតទៅ លើកលែងតែបទញ្ញត្តិចែងក្នុងប្រការ៣ និងប្រការ៤ដែលនឹងចូលជាធរមាននាថ្ងៃ ទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៦។

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៦

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

<u>ចម្លងជូន:</u>

- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ស ខេង
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងសុខាភិបាល
- ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
  (ដើម្បីជូនជ្រាប)
- ក្រសួងពត៌មាន (ដើម្បីសហការផ្សព្វផ្សាយ)
- ទីចាត់ការគយ និងរដ្ឋាករ
- គ្រប់សាលាខេត្ត-ក្រុង ( ដើម្បីសហការអនុវត្ត )
- សភាពាណិជ្ជកម្មរាជធានីភ្នំពេញ និងខេត្ត-ក្រុង (សំរាប់គោលដៅជាប្រយោជន៍)
- ឯកសារ-កាលប្បវត្តិ


Ministry of Commerce
20 A & B Preah Norodom Boulevard
Phnom Penh 12205
Kingdom of Cambodia

Senior Minister's Cabinet
Tel: (855) 23 427 358/214 946
Fax: (855) 23-213-288/991-708
E-mail: moccabdin@yahoo.com

ឧបសម្ព័ន្ធ ១ នៃប្រកាសក្រសួងពាណិជ្ជកម្មលេខៈ ១៤៣ MOC/SM 2006 ចុះថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ ២០០៦

## សារធាតុគីមីហាមប្រើលើផលិតផលម្ហូបអាហារ

| លេខរៀង | សារធាតុគីមី | CAS NUMBER |
|---|---|---|
| ០១ | BORAX | 1303-96-4 |
| ០២ | BORIC ACID | 10043-35-3 |
| ០៣ | FORMALDEHYDE | 50-00-0 |
| ០៤ | PARAFORMALDEHYDE | 30525-89-4 |
| ០៥ | PARA RED | 6410-10-2 |
| ០៦ | RHODAMINE B | 81-88-9 |
| ០៧ | SALICYLIC ACID | 69-72-7 |
| ០៨ | SUDAN I | 842-07-9 |
| ០៩ | SUDAN II | 3118-97-6 |
| ១០ | SUDAN III | 85-86-9 |
| ១១ | SUDAN IV | 85-83-6 |



Ministry of Commerce
20 A & B Preah Norodom Boulevard
Phnom Penh 12205
Kingdom of Cambodia

Senior Minister's Cabinet
Tel: (855) 23 427 358/214 946
Fax: (855) 23-213-288/991-708

ឧបសម្ព័ន្ធ ២ នៃប្រកាសក្រសួងពាណិជ្ជកម្មលេខៈ ១៨៣ ពណ.ប្រក.២០០៦ ចុះថ្ងៃទី២៨ ខែ កញ្ញា ឆ្នាំ ២០០៦

## ផលិតផលម្ហូបអាហារដែលតម្រូវមានរបាយការណ៍វិភាគ

| លេខរៀង | ផលិតផលម្ហូបអាហារ |
|---|---|
| ០១ | ផលិតផលទឹកម្ទេស |
| ០២ | ផលិតផលម្សៅម្ទេស |
| ០៣ | ផលិតផលទឹកប៉េងប៉ោះ |
| ០៤ | ផលិតផលគ្រឿងការី |
| ០៥ | ផលិតផលប្រេង Palm Oil |
| ០៦ | ផលិតផលម្សៅរមៀត (CURCUMA) |
| ០៧ | ផលិតផលទឹកជ្រលក់ដែលមានប្រើប្រាស់ផលិតផល ចំណុចទី ០១ -០២-០៣-០៤-០៥-០៦ ជាសមាសធាតុផ្សំ |
| ០៨ | ផលិតផលម្ហូបអាហារដែលមានប្រើប្រាស់ផលិតផលចំណុចទី ០១ - ០២-០៣-០៤-០៥ -០៦-០៧ ជាសមាសធាតុផ្សំ |


Ministry of Commerce
20 A & B Preah Norodom Boulevard
Phnom Penh 12205
Senior Minister's Cabinet
Tel: (855) 23 427 358/214 946
Fax: (855) 23-213-288/991-708